មជ្ឈមណ្ឌលឯកសារកម្ពុជា

**សុន្ទរកថាបិទសន្និសីទ**

ឆាំង យុ

នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា

ក្នុងពិធីបិទសន្និសីទលើកទី១ ស្តីពី «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍»

ថ្ងៃពុធ ១៥កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ត្រូវនឹងថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៤

-សូមគោរព **សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន** ប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ និងជាប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់!

-សូមគោរព ឯកឧត្តម លោកជំទាវ សមាជិក សមាជិកានៃព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល

-សូមគោរព លោកជំទាវ អាលីស វ៉ៃរីមូ ឌីរីទូ អគ្គលេខាធិការរង និង ជាទីប្រឹក្សាពិសេស របស់អង្គការសហប្រជាជាតិ ដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍

-សូមគោរព លោកជំទាវ បេិត វ៉ាន់សាក់ អគ្គរដ្ឋទូតសហរដ្ឋអាមេរិក ការិយាល័យយុត្តិធម៌ព្រហ្មទណ្ឌសកលនៃក្រសួងការប្រទេសសហរដ្ឋអាមេរិក

-សូមគោរព ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ

-សូមគោរព អ៊ំ ពូ មីង ដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងប្អូនៗដែលជាអ្នកស្រាវជ្រាវវ័យក្មេង ជាទីគោរព និងជាទីស្នេហា!

ខ្ញុំបាទ ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជានិងស្ថាបនិកព្រះរាជបណ្ណាល័យហ្លួងម៉ែ។ ស្របពេលដែលយើងគ្រោងនឹងបិទបញ្ចប់សន្និសីទលើកទី១ ក្រោមប្រធានបទ **«អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍»** ខ្ញុំបាទសូមសម្តែងអំណរគុណក្រៃលែង វត្តមានសម្តេច ឯកឧត្តម លោកជំទាវ លោក-លោកស្រី អ្នកនាងកញ្ញា ដែលបានចូលរួម ញ៉ាំងឲ្យសន្និសីទនេះប្រព្រឹត្តទៅដោយរលូន និងជោគជ័យ។

ទូលព្រះបង្គំខ្ញុំបាទសូមគោរពថ្លៃងអំណរព្រះគុណ និងអំណរគុណយ៉ាងជ្រាលជ្រៅ **ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា, សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុង



Documentation Center of Cambodia
Mansion 11, Street 256, Phnom Penh, Cambodia ♦ dccam@online.com.kh ♦ www.dccam.org
'...a society cannot know itself if it does not have an accurate memory of its own history.'
— SINCE 1995 —

សេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល, **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា, **សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងកងកម្លាំងនៃកងយោធពលខេមរភូមិន្ទ ដែលរួមមានមន្ត្រីយោធា និងមន្ត្រីនគរបាល។

ខ្ញុំបាទមានសេចក្តីដឹងគុណដល់ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិដែលតែងតែផ្តល់ជាជំនួយគាំទ្រយ៉ាងខ្ជាប់ខ្ជួន ចំពោះមជ្ឈមណ្ឌលឯកសារកម្ពុជា។ សន្និសីទលើកទី១នេះ មិនអាចប្រព្រឹត្តទៅបានឡើយប្រសិនបើពុំមានការគាំទ្រទាំងអស់ខាងលើនេះទេ។

ខ្ញុំបាទ សូមគោរពអរគុណយ៉ាងក្រៃលែង ជាថ្មីម្តងទៀតចំពោះ **ឯកឧត្តមនាយឧត្តមសេនីយ៍ ម៉ៅ សុផាន់** មេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក ដែលអនុញ្ញាតឲ្យខ្ញុំបាទ ប្រើប្រាស់ទីតាំង **សាលយុត្តិតេជោ** ដ៏មានសារសំខាន់ ដើម្បីរៀបចំសន្និសីទ ញ៉ាំងឲ្យសន្និសីទនេះប្រព្រឹត្តទៅបានយ៉ាងល្អប្រសើរ។

សន្និសីទលើកទី១នេះ គឺគ្រាន់តែជាជំហានដំបូងប៉ុណ្ណោះ ក្នុងការឈានទៅសម្រេចបានអនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍។ សន្និសីទនេះចាប់ផ្តើមដើមដំបូងជាមួយនឹងបេសកកម្មក្នុងការបង្កើតជាសហគមន៍អន្តរកាលមួយ ដោយគួបផ្សំប្រមូលផ្តុំនូវអ្នកជំនាញផ្នែកសិទ្ធិមនុស្ស និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅក្នុងសង្គមក្រោយជម្លោះ។ ខ្ញុំបាទ ទន្ទឹងរង់ចាំធ្វើការរួមសហការគ្នា ក្នុងការកសាងនូវសន្តិភាពប្រកបដោយនិរន្តរភាពនៅក្នុងប្រទេសកម្ពុជានិងសង្គមដទៃផ្សេងទៀត តាមរយៈសន្និសីទជាបន្តបន្ទាប់នាពេលអនាគត។

ជាថ្មីម្តងទៀត ខ្ញុំបាទ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា, ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ, ភ្ញៀវកិត្តិយសជាតិនិងអន្តរជាតិ, ឯកឧត្តមលោកជំទាវ លោក-លោកស្រី អ្នកនាងកញ្ញា ដែលបានចំណាយពេលចូលរួមនៅក្នុងព្រឹត្តិការណ៍ដ៏មានសារសំខាន់នាថ្ងៃនេះ និងជំរុញឲ្យសន្និសីទនេះប្រព្រឹត្តទៅដោយជោគជ័យ។